ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មានស្តីពី
# សន្និសីទស្តីពីសមិទ្ធផល២៤ឆ្នាំនៃការអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

(ដើម្បីរំលឹកខួបឆ្នាំទី២៤ទិវាប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)
អគារ « ស » វិមានរដ្ឋចំការមន ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧

នាព្រឹកនៃថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ នៅអគារ«ស»វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបានប្រារព្ធសន្និសីទស្តីពីសមិទ្ធផល២៤ឆ្នាំនៃការអនុវត្តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដើម្បីរំលឹកខួបឆ្នាំទី២៤ ទិវាប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានវាគ្មិនតំណាងក្រសួង-ស្ថាប័នជាតិនានា រួមមានៈ ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រាជបណ្ឌិត្យសភាកម្ពុជា ដែលបានធ្វើបទបង្ហាញទាក់ទងនឹងខ្លឹមសារនៃប្រធានបទ ព្រមទាំងវាយតម្លៃអំពីសមិទ្ធផល ស្នាដៃ ការងាយស្រួល ការលំបាក និង ការប្តេជ្ញាចិត្តរបស់ក្រសួង-ស្ថាប័នជាតិនានា ។ សន្និសីទនេះមានភ្ញៀវដែលជាតំណាងជាន់ខ្ពស់នៃក្រសួង-ស្ថាប័នជាតិ និងអង្គការ សង្គមស៊ីវិល អញ្ជើញចូលរួមសរុបចំនួន.......65.......នាក់ ។

ថ្លែងទៅកាន់អង្គសន្និសីទ ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានមានប្រសាសន៍ថា ដើម្បីរំលឹកខួបលើកទី២៤នៃទិវាជាប្រវត្តិសាស្ត្រ ក្រុមប្រឹក្សាធម្មនុញ្ញរៀបចំសន្និសីទខ្នាត Symposium នេះឡើងក្នុងគោលបំណងបង្ហាញឲ្យឃើញនូវគោលគំនិតធំចំនួន០២ គឺៈ

**១**-លទ្ធផលនៃការកសាង និង អនុវត្តប្រព័ន្ធច្បាប់ និង បទដ្ឋានគតិយុត្ត ដែលបានធានាបរិស្ថានអំណោយផលសម្រាប់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ។

**២**-លទ្ធផលចម្បងក្នុងការអភិវឌ្ឍប្រទេសរបស់ស្ថាប័នជាតិនានាក្នុងរយៈពេល២៤ឆ្នាំកន្លងមក ។

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញក៏បានមានប្រសាសន៍បញ្ជាក់ផងដែរថា ចាប់តាំងពីឆ្នាំ១៩៩៣ មកដល់ឆ្នាំ២០១៧ រាជរដ្ឋាភិបាល រដ្ឋសភានិងព្រឹទ្ធសភាបានកសាងមូលដ្ឋានគតិយុត្តប្រមាណ ៤៧០ដែលក្នុងនោះរួមមានៈច្បាប់ជាតិចំនួនប្រមាណ២៨១ ផ្តល់សច្ចាប័នលើលិខិតូបករណ៍និងកិច្ចព្រមព្រៀងអន្តរជាតិចំនួនប្រមាណ១៨៩ ។ យោងតាមការវាយតម្លៃទូទៅ មូលដ្ឋានច្បាប់និងបទដ្ឋានគតិយុត្តដែលត្រូវបានកសាងឡើង និង ដាក់ឲ្យអនុវត្តជាធរមានរួចហើយ មកដល់ពេលនេះអាចនិយាយបានថា ជាប្រព័ន្ធច្បាប់មួយរឹងមាំមានស្ថិរភាព អាចជឿទុកចិត្តបាន និង មានបរិមាណនិងគុណភាពសឹងគ្រប់គ្រាន់ និង គ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងសំណូមពរនៃការអភិវឌ្ឍប្រទេសជាតិមកដល់ពេលនេះ ដែលទាំងអស់នេះត្រូវបានរាប់ជាសមិទ្ធផលចម្បងក្នុងដំណើរការលើកតម្កើងឧត្តមភាពនិងកិត្យានុភាពនៃរដ្ឋធម្មនុញ្ញតាមមាគ៌ានៃនីតិរដ្ឋ។ យ៉ាងណាមិញក្នុងរយៈពេល២៤ឆ្នាំនេះ រដ្ឋធម្មនុញ្ញដែលត្រូវបានសរសេរចារឹកឡើងក្នុងឆន្ទៈមោះមុតនៃប្រជារាស្ត្រខ្មែរ ត្រូវបានធានាការពារគោរពយ៉ាងម៉ឺងម៉ាត់នៅក្នុងដំណើរមួយដ៏ប្រពៃ ដូច្នេះប្រជាពលរដ្ឋខ្មែរ ក៏ដូចភាគីពាក់ព័ន្ធទាំងអស់មានកាតព្វកិច្ចអនុវត្តបន្តការគោរពតាមស្មារតីនៃរដ្ឋធម្មនុញ្ញ បន្តការពង្រឹងស្មារតីគោរពច្បាប់ ដើម្បីធ្វើឲ្យតម្លៃនេះក្លាយជាតម្លៃរួមតែមួយ សម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ក្នុងឋានៈជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ក្នុងដំណើរកសាងប្រទេសជាតិ ឲ្យក្លាយជាកោះសន្តិភាពមួយ លូតលាស់សម្បូររុងរឿងជានិច្ចនិរន្តរ៍តទៅដែលជាបំណងដ៏ពិសិដ្ឋ ដូចបានលើកឡើងនៅក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។